E61/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ជូនចំពោះ: ឯកឧត្តម **ពេជ ឈេង** ប្រធានអង្គភាពគាំពារ ជនរងគ្រោះ    កាលបរិច្ឆេទ: ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១១

ពី: ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: ភាគីទាំងអស់នៃសំណុំរឿង០០២
លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
លោកស្រី **Lyma NGUYEN** លោកស្រី **Nushin SARKARATI** លោក **សំ សុគង់** ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

កម្មវត្ថុ: អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង តបទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំផ្លាស់ប្តូរអ្នកតំណាងផ្នែកច្បាប់នៃដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះសាលាដំបូងសូមយោងទៅលើសំណើសុំចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១១ ដែលបានស្នើសុំផ្លាស់ប្តូរអ្នកតំណាងដោយអណត្តិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង០០២ (ឯកសារE61)។

ដោយផ្អែកតាមសំណើសុំខាងលើ អង្គជំនុំជម្រះសាលាដំបូងបកស្រាយថាវិធាន ២៣ ស្ទួនពីរថា អាចអនុញ្ញាតឱ្យអង្គជំនុំជម្រះធ្វើដូច្នេះបាន ប៉ុន្តែមិនមានន័យថា វិធាននេះតម្រូវឱ្យមានការឯកភាពពីអង្គជំនុំជម្រះទាក់ទងនឹងការរៀបចំអ្នកតំណាង ឬការផ្លាស់ប្តូរអ្នកតំណាងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ជាទូទៅ អង្គជំនុំជម្រះនឹងមិនពិនិត្យលើការចាត់តាំងអ្នកតំណាងទាំងនេះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមស្នើឱ្យអង្គភាពគាំពារជនរងគ្រោះ ដោយសហការជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការរៀបចំនូវអ្នកតំណាងដោយអណត្តិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន និងនៅពេលអនាគតដែលខ្លួនយល់ថាសមស្រប ដោយមិនចាំបាច់ស្នើសុំមកអង្គជំនុំជម្រះសាលាដំបូងឡើយ។

អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យនូវសំណើសុំខាងលើ ហើយសូមបញ្ជាក់ថា អង្គជំនុំជម្រះមិនជំទាស់ទៅនឹងការផ្លាស់ប្តូរអ្នកតំណាងដោយអណត្តិដែលបានស្នើសុំនោះទេ។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 04 / 2011
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh